# ព្រឹត្តិបត្រព័ត៌មាន

## ប្រចាំខែមិថុនា ឆ្នាំ២០២៦









**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

www.trustregulator.gov.kh | www.facebook.com/trustregulatorcambodia | (855) 23 237 888

# មាតិកា


| | | |
|---|---|---|
| ១ | កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ **ន.ប.ធ.** ជាមួយក្រុមការងារសិក្សាឧត្តមានុវត្តន៍នៃបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌ (**ក.ប.ប.**) | ទំព័រទី១ |
| ២ | កិច្ចប្រជុំតម្រង់ទិសសម្រាប់ការរៀបចំផែនការថវិកាឆ្នាំ២០២៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ទំព័រទី២ |
| ៣ | ពិធីដើរកម្សាន្ត ២៧០០ ជំហានដើម្បីទារក និងកុមារកម្ពុជា | ទំព័រទី៣ |
| ៤ | កិច្ចប្រជុំលើកទី២ របស់ក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ | ទំព័រទី៤ |
| ៥ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ការធ្វើបច្ចុប្បន្នភាពបរធនបាលកិច្ចពាក់ព័ន្ធ ដែលបានបង្កើតនិងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ** | ទំព័រទី៥ |
| ៦ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ** | ទំព័រទី៥ |
| ៧ | កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) | ទំព័រទី៦ |
| ៨ | កិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៩ | ទំព័រទី៦ |
| ៩ | សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" | ទំព័រទី៧ |
| ១០ | កិច្ចប្រជុំក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | ទំព័រទី៨ |
| ១១ | សកម្មភាពមន្ត្រី **ន.ប.ធ.** ជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ សហពាណិជ្ជ ក.អ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក សម្រាប់ប្រតិបត្តិការបរ-ធនបាលកិច្ចពាណិជ្ជកម្ម | ទំព័រទី៩ |
| ១២ | កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦ | ទំព័រទី៩ |
| ១៣ | សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ទំព័រទី១០ |
| ១៤ | កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ | ទំព័រទី១០ |
| ១៥ | សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបរធនបាលកិច្ច និងប្រកាសស្តីពីការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច"បច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ" | ទំព័រទី១១ |
| ១៦ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ | ទំព័រទី១១ |

| | |
|---|---|
| ១៧ | កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦.......ទំព័រទី១២ |
| ១៨ | សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពី "ការបំពេញបន្ថែមលើប្រកាសស្តីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព".......ទំព័រទី១៣ |
| ១៩ | កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦....ទំព័រទី១៤ |
| ២០ | ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករគណនេយ្យនិងសវនកម្ម និងគណៈកម្មាធិការសហប្រតិការដើម្បីកម្ពុជា.......ទំព័រទី១៤ |
| ២១ | សកម្មភាពរបស់មន្ត្រីជំនាញនៃ **ន.ប.ធ.** ផ្តល់ការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពបច្ចេកទេសក្នុងវិស័យបរធនបាលកិច្ច.......ទំព័រទី១៥ |
| ២២ | កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**).......ទំព័រទី១៥ |
| ២៣ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ វឌ្ឍនៈ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណពី **ន.ប.ធ**.......ទំព័រទី១៦ |
| ២៤ | កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី.......ទំព័រទី១៦ |
| ២៥ | កិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច.......ទំព័រទី១៧ |
| ២៦ | កិច្ចប្រជុំស្តីពីការពិនិត្យ និងពិភាក្សាអំពី "សេចក្តីព្រាងប្រកាសស្តីពីការបង្កើតបណ្តាញអភិវឌ្ឍនិងនវានុវត្តបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ".......ទំព័រទី១៨ |
| ២៧ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អិកស៍ ត្រាស់ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល.......ទំព័រទី១៨ |
| ២៨ | សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ**.......ទំព័រទី១៩ |
| ២៩ | ពិធីសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា ដែលរៀបចំឡើងដោយធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) សហការជាមួយក្រុមហ៊ុន Mekong Strategic Capital (MSC).....ទំព័រទី១៩ |
| ៣០ | សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់".......ទំព័រទី២០ |
| ៣១ | វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ...ទំព័រទី២១ |
| ៣២ | សិក្ខាសាលា ស្តីពី "ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា".......ទំព័រទី២២ |
| ៣៣ | សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា".......ទំព័រទី២៤ |
| ៣៤ | កម្មវិធី "Sustainable Debt and Transition Finance Asia ប្រចាំឆ្នាំ២០២៦".......ទំព័រទី២៥ |

| | |
|---|---|
| ៣៥ | សកម្មភាពថ្នាក់ដឹកនាំនៃ **ន.ប.ធ.** កាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ឆ្នាំ២០២៦..........ទំព័រទី២៦ |
| ៣៦ | សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយឥណទាន និងកិច្ចពិគ្រោះយោបល់លើនីតិវិធីពាក់ព័ន្ធប្រតិបត្តិការឥណទានខ្សែ-ច្រវាក់តម្លៃកសិកម្មនៃគម្រោងប្រកួតប្រជែង ខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"..........ទំព័រទី២៧ |
| ៣៧ | សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "នីតិវិធីនៃការរៀបចំនិងការគ្រោងថវិកា និងគោលការណ៍ណែនាំបើកប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសរបស់ **ន.ប.ធ.**"..........ទំព័រទី២៨ |
| ៣៨ | សាលាផ្សព្វផ្សាយអំពី "កិច្ចគាំពារវិនិយោគិន និងពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"..........ទំព័រទី២៩ |
| ៣៩ | កម្មវិធីអបអរសាទរទិវា ជាតិសហគ្រាសធុនមីក្រូតូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦" ក្រោមប្រធានបទ "សាងស្ពានសម្រាប់ MSMEs ឆ្ពោះទៅកាន់ទីផ្សារ..........ទំព័រទី៣០ |
| ៤០ | សិក្ខាសាលាស្ដីពី "ការបង្កើត និងចុះបញ្ជីបរធនបាលកិច្ច អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដល់អង្គការសមាគមស្ថិតក្រោមក្រសួងមហាផ្ទៃ..........ទំព័រទី៣១ |
| ៤១ | កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦..........ទំព័រទី៣២ |
| ៤២ | កិច្ចប្រជុំក្រុមការងារចំពោះកិច្ចទទួលបន្ទុករៀបចំការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល..........ទំព័រទី៣៣ |
| ៤៣ | សិក្ខាសាលាស្ដីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"..........ទំព័រទី៣៤ |
| ៤៤ | កិច្ចប្រជុំពិភាក្សាលើកទី២ លើសេចក្ដីព្រាងច្បាប់ស្ដីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥..........ទំព័រទី៣៥ |
| ៤៥ | វគ្គបណ្ដុះបណ្ដាលស្ដីពី "កាតព្វកិច្ចផ្ដល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ដល់បរធនបាលនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ **ន.ប.ធ**..........ទំព័រទី៣៥ |
| ៤៦ | មន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្មដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធនដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ**..........ទំព័រទី៣៦ |

# ព្រឹត្តិបត្រព័ត៌មានរបស់ ន.ប.ធ.

**ប្រចាំខែមិថុនា | លេខ ៦០**

**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## សេចក្តីសង្ខេបព្រឹត្តិការណ៍សំខាន់ៗប្រចាំខែ

### ប្រតិបត្តិករ និងអ្នកផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច

| | | |
|---|---|---|
| **១៦**<br>ក្រុមហ៊ុនបរធនបាល | **២៩**<br>ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុក | **២៩**<br>បរធនបាលរូបវន្តបុគ្គលឯករាជ្យ |
| **៤៣**<br>បរធនបាលរូបវន្តបុគ្គលនៃក្រុមហ៊ុនបរធនបាល | **១៩**<br>ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច | **១៥**<br>ក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច |
| **សរុប** | **បរធនបាលកិច្ច ត្រូវបានបង្កើត និងចុះបញ្ជី**<br>**១,៩៧៤ ករណី** | **ទំហំបរធនប្រមាណ**<br>**២,៦៧២ លានដុល្លារអាមេរិក** |

**ចំនួនបរធនបាលដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងក្រុមហ៊ុនទទួលបានការទទួលស្គាល់**



# ទិន្នន័យប្រតិបត្តិការក្នុងវិស័យបរធនបាលកិច្ច

## គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦

## ចំនួនបរធនបាលកិច្ចដែលបានចុះបញ្ជីនៅ ន.ប.ធ.

| ប្រភេទបរធនបាលកិច្ច | ចំនួន | ទំហំបរធន |
|---|---|---|
| បរធនបាលកិច្ចសាធារណៈ | ៣ | $ ១២១,៦៣៨,៩១០ |
| បរធនបាលកិច្ចហិរញ្ញវត្ថុ | ៩ | $ ៥០៥,៦២៧,៤៥២ |
| បរធនបាលកិច្ចពាណិជ្ជកម្ម | ១,៩៤៩ | $ ២,០៤០,៨៤៣,៩៦១.៦៣ |
| បរធនបាលកិច្ចសង្គម | ៣ | $ ១,៩៩៨,៥៣១.៤៩ |
| បរធនបាលកិច្ចបុគ្គល | ១០ | $ ២,៧៤៥,១៩២.៤៨ |
| **សរុប** | **១,៩៧៤** | **$ ២,៦៧២,៨៥៤,០៤៧.៦០** |



## ព័ត៌មានលម្អិតនៃបច្ចុប្បន្នភាពប្រចាំខែ

ខាងក្រោមនេះ គឺជាព័ត៌មានលម្អិតអំពីសកម្មភាព និងបច្ចុប្បន្នភាពសំខាន់ៗរបស់និយ័តករបរធនបាលកិច្ច ដែលត្រូវបានបញ្ចូលក្នុងព្រឹត្តិបត្រប្រចាំខែនេះ៖

### ១. កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមការងារសិក្សាឧត្តមានុវត្តន៍នៃបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌ (ក.ប.ប.)




*រូបភាព៖ កិច្ចប្រជុំរវាងថ្នាក់ដឹកនាំ ន.ប.ធ. ជាមួយក្រុមការងារសិក្សាឧត្តមានុវត្តន៍នៃបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌ (ក.ប.ប.)។*

នៅថ្ងៃអង្គារ ២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** មានមតិសំណេះសំណាលជាមួយក្រុមការងារសិក្សាឧត្តមានុវត្តន៍នៃបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌ (**ក.ប.ប.**) ដែលមាន **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច និងជាប្រធាន ក.ប.ប.**, **លោក រិន វង្ឃា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងជាអនុប្រធាន ក.ប.ប.**, ព្រមទាំងសមាជិកពី **ន.ប.ធ.** និងសមាជិកពីក្រុមហ៊ុនបរធនបាល និងប្រតិបត្តិករបរធនបាល។

កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណងពិភាក្សាលើការសិក្សាក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌបច្ចេកទេសពាក់ព័ន្ធនឹងការបង្កើត ការចុះបញ្ជី ការគ្រប់គ្រងបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌ ព្រមទាំងកំណត់ទិសដៅការងារបន្ត ដើម្បីជំរុញការអភិវឌ្ឍទីផ្សារបរធនបាលកិច្ចគ្រួសារ និងបរធនបាលកិច្ចសប្បុរសធម៌នៅកម្ពុជា ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងទំនុកចិត្តក្នុងវិស័យបរធនបាលកិច្ច។

## ២. កិច្ចប្រជុំតម្រង់ទិសសម្រាប់ការរៀបចំផែនការថវិកាឆ្នាំ២០២៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ




*រូបភាព៖ កិច្ចប្រជុំតម្រង់ទិសសម្រាប់ការរៀបចំផែនការថវិកាឆ្នាំ២០២៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។*

នាព្រឹកថ្ងៃពុធ ៣រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំតម្រង់ទិសសម្រាប់ការរៀបចំផែនការថវិកាឆ្នាំ២០២៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**កសហវ**) និងការស្នើរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៧-២០២៩, គម្រោងថវិកាឆ្នាំ២០២៧, និងគម្រោងសមិទ្ធកម្មឆ្នាំ២០២៧ របស់អង្គភាពថវិកា នៃ **កសហវ** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការ** នៃ **កសហវ** និង **ឯកឧត្តមរដ្ឋលេខាធិការ កសហវ** ដែលជាប្រធានកម្មវិធីនៃអង្គភាពថវិកា **កសហវ** ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** នៅសណ្ឋាគារសុខាភ្នំពេញ។

## ៣. ពិធីដើរកម្សាន្ត ២៧០០ ជំហានដើម្បីទារក និងកុមារកម្ពុជា




*រូបភាព៖ ពិធីដើរកម្សាន្ត ២៧០០ ជំហានដើម្បីទារក និងកុមារកម្ពុជា។*

នារសៀលថ្ងៃព្រហស្បតិ៍ ៤រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមក្នុង "ពិធីដើរកម្សាន្ត ២៧០០ ជំហានដើម្បីទារក និងកុមារកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាបរធនបាលនៃមូលនិធិគន្ធបុប្ផាកម្ពុជា** និងមានអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** ដែលបានធ្វើឡើងនៅពហុកីឡដ្ឋានជាតិមរតកតេជោ ព្រមទាំងបានពាំនាំថវិកាឧបត្ថម្ភពីថ្នាក់ដឹកនាំ និងមន្ត្រី **ន.ប.ធ.** ប្រគល់ជូនផងដែរ។

## ៤. កិច្ចប្រជុំលើកទី២ របស់ក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ




*រូបភាព៖ កិច្ចប្រជុំលើកទី២ របស់ក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ។*

នារសៀលថ្ងៃសុក្រ ៥រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ អមដោយ **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី២ របស់ក្រុមការងារជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីពិនិត្យនិងពិភាក្សាលើ "សេចក្ដីព្រាងផែនការយុទ្ធសាស្ត្របរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ២០២៦-២០៣០" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** (**អ.ស.ហ.**) និងមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅទីស្ដីការ **អ.ស.ហ.**។

## ៥. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ការធ្វើបច្ចុប្បន្នភាពបរធនបាលកិច្ចពាក់ព័ន្ធ ដែលបានបង្កើតនិងចុះបញ្ជីបរធនបាលកិច្ចនៅ ន.ប.ធ.




*រូបភព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ការធ្វើបច្ចុប្បន្នភាពបរធនបាលកិច្ចពាក់ព័ន្ធ ដែលបានបង្កើតនិងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.**។*

នៅថ្ងៃព្រហស្បតិ៍ ៤រោច និងថ្ងៃសុក្រ ៥រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៤-៥ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះអធិការកិច្ច ដើម្បីផ្ទៀងផ្ទាត់ការធ្វើបច្ចុប្បន្នភាពបរធនបាលកិច្ចពាក់ព័ន្ធ ដែលបានបង្កើតនិងចុះបញ្ជីបរ-ធនបាលកិច្ចនៅ **ន.ប.ធ.** ដែលស្ថិតនៅខេត្តតាកែវ និងខេត្តព្រះសីហនុ។

## ៦. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ ន.ប.ធ.




*រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.**។*

នៅថ្ងៃសុក្រ ៥ រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួល-បានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គម និងបុគ្គល** នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ចស្ថិតនៅខេត្តកំពង់ស្ពឺ ដែលបានស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** និងកំពុងធ្វើប្រតិបត្តិការដោយបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។

## ៧. កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)





*រូបភាព៖ កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។*

នារសៀលថ្ងៃចន្ទ ៨រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦, **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងរបាយការណ៍សមិទ្ធកម្មសម្រាប់អាណត្តិទី១ របស់ **អ.ស.ហ.** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ Zoom ។

## ៨. កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៩





*រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៩។*

នាព្រឹកថ្ងៃអង្គារ ៩រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការចូលរួមពី ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ ឯកឧត្តមអគ្គនាយក និយ័តករក្រោមឱវាទនៃ **អ.ស.ហ.** និងសមាជិក-សមាជិកា **អ.ស.ហ.** ព្រមទាំងថ្នាក់ដឹកនាំនៃនិយ័តករនិងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ដោយផ្ទាល់នៅទីស្តីការ **អ.ស.ហ.**។

## ៩. សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"




*រូបភាព៖ សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"។*

នាព្រឹកថ្ងៃពុធ ១០រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក កៀន តាក់ សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** នៅសាកល-វិទ្យាល័យភូមិន្ទភ្នំពេញ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ,សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## ១០. កិច្ចប្រជុំក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ



*រូបភាព៖ កិច្ចប្រជុំក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។*

នាព្រឹកថ្ងៃពុធ ១០រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៦ នៅធនាគារជាតិនៃកម្ពុជា (**អគារសែនសុខ**) ដោយមានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** អមដោយសហការីបានចូលរួមកិច្ចប្រជុំក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិនិងត្រៀម និងទទួលការវាយតម្លៃអញ្ញមញ្ញ ឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ហេង បូមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលបានអញ្ជើញជាសហប្រធានជាមួយ **ឯកឧត្តម ហាក់ សុខហេង អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងជាអនុប្រធានគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ**។ កិច្ចប្រជុំនេះផ្តោតទៅលើ ១-សេចក្តីសង្ខេបនៃយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្មឆ្នាំ២០១៩-២០២៣, ២-នីតិវិធីវាយតម្លៃអញ្ញមញ្ញសកលជុំទី៥ របស់ APG និង ៣-ការកំណត់កាលវិភាគនៃដំណើរការវាយតម្លៃអញ្ញមញ្ញនៅកម្ពុជា កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នសមាជិកពាក់ព័ន្ធ។

## ១១. សកម្មភាពមន្ត្រី ន.ប.ធ. ជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ សហពាណិជ្ជ ក.អ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម




*រូបភាព៖ សកម្មភាពមន្ត្រី **ន.ប.ធ.** ជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ សហពាណិជ្ជ ក.អ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក សម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។*

នាព្រឹកថ្ងៃពុធ ១០រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ., លោក រិន វដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច**នៃ **ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ សហពាណិជ្ជ ក.អ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។

## ១២. កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦



*រូបភាព៖ ប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦។*

នាព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម នាង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ ក៏មានការចូលរួមពីលោកស្រីប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០២៦ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។

## ១៣. សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ




*រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។*

នៅថ្ងៃព្រហស្បតិ៍ ១១រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១១ ខែ១១ ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ឆែម លាបហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** បានអញ្ជើញចូលរួមជាវាគ្មិនក្នុង "សិក្ខាសាលាផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** និងមានការចូលរួមពីតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**, រដ្ឋបាលខេត្តកំពង់ឆ្នាំង, ស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ព្រមទាំងសិស្សនិស្សិត សាស្ត្រាចារ្យ អាជីវករ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅសណ្ឋាគារ រស្មីសុខា ញ៉ូយ៉ក ក្នុងខេត្តកំពង់ឆ្នាំង។

## ១៤. កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥




*រូបភាព៖ កិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។*

នាព្រឹកថ្ងៃសុក្រ ១២ រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦, **លោក ឃុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក លឹម ឡែត ប្រធានស្តីទីនាយកដ្ឋានកិច្ចការទូទៅ** និងសហការីបានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើកទី១ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ជូ គឹមខ្សេង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ Zoom។

## ១៥. សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបរធនបាលកិច្ច និងប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច"បច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"



*រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបរធនបាលកិច្ចនិងប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច"បច្ចេកវិទ្យាហិរញ្ញវត្ថុនិងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ"។*

នៅព្រឹកថ្ងៃសុក្រ ១២រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបរធនបាលកិច្ច និងប្រកាសស្ដីពីការដោះស្រាយវិវាទក្នុងវិស័យបរធនបាលកិច្ច" ដល់បរធនបាល ប្រតិបត្តិករបរធនបាល និងតួអង្គពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្ដីការអោជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងដល់តួអង្គពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច អំពីយន្តការ បែបបទ និងនីតិវិធីនៃការដោះស្រាយវិវាទសសទក្នុងវិស័យបរធនបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព គណនេយ្យភាព និងអនុលោមភាពច្បាប់ពាក់ព័ន្ធជាធរមាន។

## ១៦. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ




*រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ។*

ចាប់ពីថ្ងៃពុធ ១០រោច ដល់ថ្ងៃសុក្រ ១២រោច ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១០-១២ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គម និងបុគ្គល** និង **លោក អ៊ឹង ឡេង ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិត-នៅខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្ដែងនៃទ្រព្យសម្បត្តិបរធន-បាលកិច្ច ដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** និងកំពុងធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។

## ១៧. កិច្ចប្រជុំគណៈកម្មការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦




*រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦។*

នាព្រឹកថ្ងៃចន្ទ ១កើត ខែបឋមសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក លឹម ឡែត ប្រធានស្តីទីនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីត្រួតពិនិត្យ និងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតអគ្គសាចារ្យ អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។

## ១៨. សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព"




*រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព"។*

នៅព្រឹកថ្ងៃចន្ទ ១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦ **ន.ប.ធ.** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្ដីពី "ការបំពេញបន្ថែមលើប្រកាសស្ដីពីកម្រៃសេវានៃការចុះបញ្ជីបរធនបាលកិច្ច ចំពោះសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅសណ្ឋាគារ រ៉េស៊ីដង់ សុខាភ្នំពេញ។ សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់ក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្ដល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកបរធនបាលរូបវន្តបុគ្គលឯករាជ្យ ក្រុមហ៊ុនផ្ដល់សេវាសវនកម្ម ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច សំដៅដល់ការអនុវត្តប្រកបដោយគណនេយ្យភាព និងប្រសិទ្ធភាពនៃការចុះបញ្ជីបរធនបាលកិច្ចចំពោះសេវារក្សាសុវត្ថិភាព ឬសេវា-រក្សាទុកសម្រាប់ប្រអប់សុវត្ថិភាព ដោយអនុលោមតាមច្បាប់ស្ដីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចជាធរមាន។

## ១៩. កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦




*រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦។*

នារសៀលថ្ងៃចន្ទ ១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែឧសភា ឆ្នាំ២០២៦ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៦ ក្នុងកម្រិតអន្តរនាយកដ្ឋាន របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធាននាយកដ្ឋាន, លោកស្រីអនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០២៦ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។

## ២០. ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករគណនេយ្យនិងសវនកម្ម និង គណៈកម្មាធិការសហប្រត្តិការដើម្បីកម្ពុជា





*រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង និយ័តករគណនេយ្យនិងសវនកម្ម និងគណៈកម្មាធិការសហប្រត្តិការដើម្បីកម្ពុជា។*

នាព្រឹកថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អ្នដស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួម ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករគណនេយ្យនិងសវនកម្ម និងគណៈកម្មាធិការសហប្រត្តិការដើម្បីកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យនិងសវនកម្ម និង **លោក ច័ន្ទ ភក្តី នាយកប្រតិបត្តិការគណៈកម្មាធិការសហប្រត្តិការដើម្បីកម្ពុជា** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅអគារការិយាល័យ ៣៤៥។

## ២១. សកម្មភាពរបស់មន្ត្រីជំនាញនៃ ន.ប.ធ. ផ្ដល់ការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពបច្ចេកទេសក្នុងវិស័យបរធនបាលកិច្ច




*រូបភាព៖ សកម្មភាពរបស់មន្ត្រីជំនាញនៃ ន.ប.ធ. ផ្ដល់ការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពបច្ចេកទេសក្នុងវិស័យបរធនបាលកិច្ច។*

នាព្រឹកថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** អមដោយសហការី បានចូលរួមផ្ដល់ការចែករំលែកចំណេះដឹងពាក់ព័ន្ធនឹងទិដ្ឋភាពច្បាប់ និងទិដ្ឋភាពបច្ចេកទេសក្នុងវិស័យបរធនបាលកិច្ច ដល់ការិយាល័យមេធាវី សុក ស៊ីផាន់ណា សិង្ហាល័យ ដែលមានការចូលរួមពី **លោកស្រីមេធាវី សុខ វណ្ណសិកា** ព្រមទាំងមេធាវី និងបុគ្គលិក នៃការិយាល័យមេធាវី សុក ស៊ីផាន់ណា សិង្ហាល័យ។

## ២២. កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)




*រូបភាព៖ កិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។*

នារសៀលថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក លឹម ឡៃត ប្រធានស្ដីទីនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំបច្ចេកទេស នៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ Zoom ។

## ២៣. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ វឌ្ឍនៈ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណពី ន.ប.ធ.







*រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ វឌ្ឍនៈ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណពី **ន.ប.ធ.**។*

នាព្រឹកថ្ងៃពុធ ៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនា យកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះ-ត្រួតពិនិត្យដល់ទីកន្លែងរបស់ធនាគារ វឌ្ឍនៈ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលសសកិច្ចសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម។

## ២៤. កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី







*រូបភាព៖  កិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី។*

នារសៀលថ្ងៃអង្គារ ២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក រិន រដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានដឹកនាំមន្ត្រីជំនាញនៃ **ន.ប.ធ.** ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រុមការងារបច្ចេកទេសនៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" (**ម.ធ.ត.**) ដឹកនាំដោយ **លោកស្រី ហ៊ាន ឡូរីដា នាយករងនៃ ម.ធ.ត.** តាមប្រព័ន្ធអនឡាសសញ (Zoom)។

កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងារ និងជំរុញការអភិវឌ្ឍសេវាចំនួន ២ របស់ **ន.ប.ធ.** ដែលបានដាក់បញ្ចូលនៅក្នុងផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨"។

## ២៥. កិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច



*រូបភាព៖ កិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច។*

នាព្រឹកថ្ងៃពុធ ៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក រិន វដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ដើម្បីពិនិត្យលើវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារបន្តសម្រាប់ធុរកិច្ចឆ្នាំ២០២៧ លើផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្ដីពី "ការអភិវឌ្ឍសេវាអេឡិចត្រូនិចសម្រាប់ធុរកិច្ចឆ្នាំ ២០២៥-២០២៨" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** (**កសហវ**) **និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល** ព្រមទាំងជាប្រធានក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច នៅសាលប្រជុំអគារ "ឃ" នៃទីស្ដីការ **កសហវ**។

## ២៦. កិច្ចប្រជុំស្តីពីការពិនិត្យ និងពិភាក្សាអំពី "សេចក្តីព្រាងប្រកាសស្តីពីការបង្កើតបណ្តាញអភិវឌ្ឍនិងនវានុវត្តបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"



*រូបភាព៖ កិច្ចប្រជុំស្តីពីការពិនិត្យ និងពិភាក្សាអំពី "សេចក្តីព្រាងប្រកាសស្តីពីការបង្កើតបណ្តាញអភិវឌ្ឍនិងនវានុវត្តបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។*

នាព្រឹកថ្ងៃសុក្រ ៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័ តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក រិន វដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** អមដោយ **លោក បេស ចាន់ដេត ប្រធានការិយាល័យគ្រប់គ្រងព័ត៌មានវិទ្យា** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងពិភាក្សាពី "សេចក្តីព្រាងប្រកាសស្តីពីការបង្កើតបណ្តាញអភិវឌ្ឍនិងនវានុវត្តបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ក្រោមការដឹកនាំរបស់ **ឯកឧត្តម សូ សុភា ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.** និងមានការអញ្ជើញចូលរួមពី លោក លោកស្រីដែលជាតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** នៅបន្ទប់ប្រជុំមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។

## ២៧. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អិកស៍ ត្រាស់ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល



*រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អិកស៍ ត្រាស់ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល។*

នាព្រឹកថ្ងៃសុក្រ ៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃ ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញចុះត្រួតពិនិត្យដល់ទីកន្លែងរបស់ក្រុមហ៊ុន អិកស៍ ត្រាស់ ដើម្បីពិនិត្យ និងផ្ទៀងផ្ទាត់ការស្នើសុំបន្តអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាល។

## ២៨. សកម្មភាពមន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ ន.ប.ធ.



*រូបភាព៖ សកម្មភាពមន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.**។*

ចាប់ពីថ្ងៃចន្ទ ១កើត ដល់ថ្ងៃសុក្រ ៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៥-១៩ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បានដឹកនាំ មន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកំពត ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ច ដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** និងកំពុងធ្វើប្រតិបត្តិការដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។

## ២៩. ពិធីសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា ដែលរៀបចំឡើងដោយ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) សហការជាមួយ ក្រុមហ៊ុន Mekong Strategic Capital (MSC)



*រូបភាព៖ ពិធីសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា ដែលរៀបចំឡើងដោយ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) សហការជាមួយក្រុមហ៊ុន Mekong Strategic Capital (MSC)។*

ដោយមានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), នាព្រឹកថ្ងៃពុធ ៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៦, **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី បានអញ្ជើញចូលរួមក្នុងពិធីសម្ពោធដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីហិរញ្ញប្បទានអាកាសធាតុនៅកម្ពុជា ដែលរៀបចំឡើងដោយ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) សហការជាមួយក្រុមហ៊ុន Mekong Strategic Capital (MSC) នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។

## ៣០. សិក្ខាសាលាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់”




*រូបភាព៖ សិក្ខាសាលាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់”។*

ចាប់ពីថ្ងៃពុធ ៣កើត ដល់ថ្ងៃសុក្រ ៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់កសិធុរកិច្ច សមាជិកសហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់” ក្រោមការដឹកនាំរបស់ **លោក លឹម ឡៃ្យត ប្រធានស្តីទីនាយកដ្ឋានកិច្ចការទូទៅនៃ ន.ប.ធ. និងជាអនុប្រធានផ្នែកគណនេយ្យនិងហិរញ្ញវត្ថុនៃគម្រោង** ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសាវតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុរកិច្ច ដល់សមាជិកនៃសហគមន៍កសិកម្មចម្រុះស្ទឹងកាច់ជឿនលឿន សហគមន៍កសិកម្មអូរអើលមហាសាមគ្គី សហគមន៍កសិកម្មកសិកររុងរឿង សហគមន៍កសិកម្មពន្លឺសាមគ្គីកសិករ និងសហគមន៍កសិកម្មរតនៈក្រចាប់មានជ័យ ដែលស្ថិតនៅស្រុកសាលាក្រៅ និងស្រុកប៉ៃលិន ខេត្តប៉ៃលិន ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិកសហគមន៍កសិកម្ម និងកសិធុរកិច្ចខាងលើ, មន្ត្រី និងទីប្រឹក្សារបស់គម្រោង ACSEP-PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន, និងស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។

## ៣១. វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៩



*រូបភាព៖ វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៩។*

នាព្រឹកថ្ងៃចន្ទ ៨កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការីបានអញ្ជើញប្រកាសបើក "វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច លើកទី៩" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ច នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ វគ្គបណ្ដុះបណ្ដាលនេះ ត្រូវបានរៀបចំរយៈពេលចំនួន បី ថ្ងៃពេញ ចាប់ពីថ្ងៃទី២២-២៤ ខែមិថុនា ឆ្នាំ២០២៦ និងមានអ្នកចូលរួមសរុបចំនួន ១៧៣ រូប ដែលមានសមាសភាពចូលរួមពីក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច, បុគ្គលដែលមានបំណងផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច និងសាធារណជន។

នាឱកាសថ្លែងបើកកម្មវិធីខាងលើ **ឯកឧត្តម សុខ ដារ៉ា** បានធ្វើការចែករំលែកដល់សិក្ខាកាមទាំងអស់ថា "វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិ ជាបុរេលក្ខខណ្ឌសម្រាប់បុគ្គលដែលត្រូវចូលរួមជាមួយក្រុមហ៊ុននិងបុគ្គលពាក់ព័ន្ធដែលផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលដែលមានបំណងផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច និងបុគ្គលដែលមានបំណងផ្ដល់សេវាក្នុងវិស័យបរធនបាលកិច្ច ហើយវគ្គបណ្ដុះបណ្ដាលនេះ ក៏ជាលក្ខខណ្ឌតម្រូវមួយក្នុងការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត/ការទទួលស្គាល់ពី **ន.ប.ធ.** ផងដែរ។ វគ្គបណ្ដុះបណ្ដាលនេះ មានរយៈពេល បី ថ្ងៃពេញ និងផ្ដោតលើទិដ្ឋភាពពីរសំខាន់ៗ គឺផ្នែកក្របខណ្ឌច្បាប់និងបទប្បញ្ញត្តិ និងផ្នែកបច្ចេកទេស ហើយសិក្ខាកាមដែល

ជាសិក្ខាកាមថ្មី ត្រូវប្រឡងគុណវុឌ្ឍិនៅក្នុងថ្ងៃទីបួនបន្ទាប់ពីវគ្គបណ្តុះបណ្តាលបានបញ្ចប់។ ក្នុងករណីប្រឡងជាប់ សិក្ខាកាមនឹងទទួលបានវិញ្ញាបនបត្រ (Certificate) ដែលជាឯកសារផ្លូវការ ដែលបញ្ជាក់ពីការបំពេញលក្ខខណ្ឌនៃការចូលរួមវគ្គបណ្តុះបណ្តាល និងប្រឡងជាប់ដោយជោគជ័យ និងមានសុពលភាពរយៈពេល ពីរ ឆ្នាំ។ ជាមួយគ្នានេះ **ន.ប.ធ.** ក៏បានរៀបចំកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ចក្នុងពេលជាមួយគ្នានេះផងដែរ សម្រាប់ក្រុមហ៊ុន និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច ដែលធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាល និងប្រឡងជាប់ដោយជោគជ័យពីមុនរួចហើយ ប៉ុន្តែផុតសុពលភាពពីរឆ្នាំ ដូចបានបញ្ជាក់ខាងលើ។ ពេលគឺសិក្ខាកាមទាំងនោះ ត្រូវមកចូលរួមកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ដើម្បីបន្តសុពលភាព ប៉ុន្តែមិនតម្រូវឱ្យធ្វើការប្រឡងឡើងវិញនោះទេ។" បន្ថែមពីនេះ **ឯកឧត្តម សុខ ដារ៉ា** ក៏បានធ្វើការចែករំលែកដល់សិក្ខាកាមទាំងអស់អំពីស្ថានភាពទូទៅនៃទីផ្សារបរធនបាលកិច្ចកាលានុវត្តភាព និងទស្សនទាននៃការអភិវឌ្ឍផលិតផលបរធនបាលកិច្ចថ្មីៗ និងទិសដៅបន្តក្នុងការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ផងដែរ ដើម្បីត្រៀមខ្លួនក្នុងការចាប់យកឱកាសថ្មីៗនៅក្នុងវិស័យបរធនបាលកិច្ច។

គួរបញ្ជាក់ជូនផងដែរថា កន្លងមក **ន.ប.ធ.** ធ្លាប់បានរៀបចំវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្តក្នុងវិស័យបរធនបាលកិច្ច ចំនួន ៨ លើក រួចមកហើយ ដោយមានអ្នកចូលរួមសរុបចំនួនប្រមាណ ១,៤០០ រូប និងមានអ្នកប្រឡងជាប់សរុបចំនួនប្រមាណ ១,៣២៣ រូប។

## ៣២. សិក្ខាសាលា ស្តីពី "ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា"




*រូបភាព៖ សិក្ខាសាលា ស្តីពី "ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា"។*

នារសៀលថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦ **ន.ប.ធ.** បានរៀបចំសិក្ខាសាលា ស្តីពី "ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា" ក្រោមអធិបតីភាព

**ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ កម្មវិធីនេះ ត្រូវបានរៀបចំឡើង ក្នុងមានគោលបំណងដើម្បីឱ្យមានកិច្ចពិភាក្សាស៊ីជម្រៅក្នុងចំណោមអ្នកជំនាញអំពីទិដ្ឋភាពទូទៅនៃការវិវត្តកាលានុវត្តភាព បញ្ហាប្រឈម និងដំណោះស្រាយយុទ្ធសាស្ត្រក្នុងវិស័យបរធនបាលកិច្ច ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ និងតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុកក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងបុគ្គលផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងសិក្ខាកាមនៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ និងកម្មវិធីអប់រំវិជ្ជាជីវៈបន្ត ក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ផងដែរ។ កម្មវិធីនេះ មានកិច្ចពិភាក្សាសំខាន់ៗចំនួន ២ ដូចខាងក្រោម៖

កិច្ចពិភាក្សាទី១ ស្តីពី "ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា" ដោយមានការសម្របសម្រួលរបស់ **លោក ណង សេរីវុធ អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការនៃ ន.ប.ធ.** និងមានការចូលរួមជាវាគ្មិនកិត្តិយសដែលជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច វិស័យធនាគារ វិស័យ ច្បាប់ និងវិស័យឯកជន រួមមាន **ឧកញ៉ា តាន់ គីម៉េង ប្រធានសមាគមសភាពាណិជ្ជកម្មម៉ាឡេស៊ីនៅកម្ពុជា និងជាអគ្គនាយកនៃក្រុមហ៊ុន** បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក, **ឯកឧត្តម ផូង សំអី** បរធនបាលរូបវន្តបុគ្គលឯករាជ្យនៃបរធនបាលកិច្ច **ហិរញ្ញវត្ថុសីលានិធិ និងជាប្រធាននៃមន្ទីរសារការីខេមរា**, **លោក** ONG TEONG HOON ប្រធានក្រុមហ៊ុន **ហ្វីលីពឡាយហ្វ៍** អាស្សូរេន (ខេមបូឌា) អ.ក. និងជាប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក, **លោក PAUL SHINWOONG YANG អគ្គនាយកគ្រប់គ្រង និងមេធាវីនៃក្រុមហ៊ុន អេសអិម គ្លូបិល គ្រុប, លោក ជា ហាង អនុប្រធាននាយកប្រតិបត្តិ និងជាអភិបាលរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហ្វីសហ្វាយនែន ភីអិលស៊ី** និង **លោកស្រី LIN-SHERRY JIAXAIO នាយកប្រតិបត្តិនៃក្រុមហ៊ុន កាណា ត្រាស ឯ.ក**។ កិច្ចពិភាក្សានេះ បានផ្តោតជាសំខាន់លើបច្ចុប្បន្នភាពនៃវិស័យបរធនបាលកិច្ច, អត្ថប្រយោជន៍នៃការប្រើប្រាស់យន្តការបរធនបាលកិច្ចក្នុងធុរកិច្ច, បទពិសោធន៍ក្នុងការអនុវត្ត, គម្លាត និងបញ្ហាប្រឈមក្នុងវិស័យបរធនបាលកិច្ច និងការផ្តល់នូវអនុសាសន៍។ ជាលទ្ធផលនៃកិច្ចពិភាក្សាអ្នកជំនាញយល់ឃើញថា៖

១. វិស័យបរធនបាលកិច្ចនៅកម្ពុជាស្ថិតក្នុងដំណាក់កាលអភិវឌ្ឍនៅឡើយ ប៉ុន្តែវិស័យនេះមានមូលដ្ឋានគ្រឹះផ្នែកច្បាប់ និងបទប្បញ្ញត្តិសំខាន់ៗរួចហើយ និងមានសក្តានុពលរឹងមាំក្នុងការរីកចម្រើនបន្ថែម។

២. យន្តការបរធនបាលកិច្ច មិនត្រឹមតែជាចំណងឬទំនាក់-ទំនងគតិយុត្តប៉ុណ្ណោះទេ ប៉ុន្តែក៏ជាយន្តការហិរញ្ញវត្ថុ និងស្ថាប័ន ដែលអាចគាំទ្រដល់ការគ្រប់គ្រងទ្រព្យសម្បត្តិ បង្កើនទំនុកចិត្តវិនិយោគ ការរចនាសម្ព័ន្ធអាជីវកម្ម ការធ្វើផែនការបន្តវេនគ្រួសារ អភិបាលកិច្ច និងការធ្វើផែនការរយៈពេលវែង។

៣. មានកត្តាពាក់ព័ន្ធជាច្រើនដែលនឹងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យបរធនបាលកិច្ច ដែលក្នុងនោះរួមមានការយល់ដឹងកាន់តែស៊ីជម្រៅរបស់សាធារណជន ភាពច្បាស់លាស់ផ្នែកច្បាប់ សមត្ថភាពវិជ្ជាជីវៈរបស់បរធនបាល ភាពច្បាស់លាស់ផ្នែកពន្ធ ទំនុកចិត្តទីផ្សារ និងបទពិសោធន៍ជោគជ័យជាក់ស្តែងក្នុងការអនុវត្ត។ ជាការចែករំលែកអំពីទស្សនវិស័យក្នុងការបន្តអភិវឌ្ឍវិស័យបរធនបាលកិច្ចក្នុងដំណាក់កាលបន្ទាប់អ្នកជំនាញបានផ្តល់យោបល់ថាមិនគួរផ្តោតត្រឹមតែលើកំណើនចំនួនបរធនបាលកិច្ចប៉ុណ្ណោះទេ ប៉ុន្តែគួរផ្តោតទៅលើគុណភាព វិជ្ជាជីវៈ និងការប្រព្រឹត្តប្រកបដោយការទទួលខុសត្រូវរបស់បរធនបាល ដើម្បីធានាដល់ការអភិវឌ្ឍប្រកបដោយចីរភាព។

កិច្ចពិភាក្សាទី២ ស្តីពី "បញ្ហាប្រឈមក្នុងការអនុវត្ត៖ ការបង្កើត និងការចុះបញ្ជីបរធនបាលកិច្ច" ដោយមានការសម្របសម្រួលរបស់ **លោក រិន វឌ្ឍា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** នៃ **ន.ប.ធ.** និងមានការចូលរួមជាវាគ្មិនកិត្តិយសដែលជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច រួមមាន៖ **ឧកញ៉ា ហួត អៀងតុង ប្រធានក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ វ៉េលហ្វ៊ី, លោក ជា ផល្លារិន បរធនបាលរូបវន្តបុគ្គលឯករាជ្យនៃបរធនបាលកិច្ចហិរញ្ញវត្ថុ** អមតៈ, **លោក គង់ ប៊ុននរិទ្ធ សមាជិកក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន** Lion Trust Cambodia, **លោក ព្រឿង សុភាព នាយកគ្រប់គ្រងទូទៅនៃក្រុមហ៊ុន ហ្វីលីព ត្រាសធី (ខេមបូឌា) ឯ.ក** និង **លោក ឌី វ៉ាន់ថាត ប្រធាននៃអគ្គនាយកដ្ឋាននីតិកម្មនៃធនាគារវឌ្ឍនៈអាស៊ីចំកាត់។**

កិច្ចពិភាក្សានេះ បានផ្តោតជាសំខាន់លើការចែករំលែកចំណេះដឹង និងបទពិសោធន៍ជាក់ស្តែងពាក់ព័ន្ធនឹងការស្នើសុំបង្កើតនិងចុះបញ្ជីបរធនបាលកិច្ច ការអនុវត្តកាតព្វកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រង ចាត់ចែង និងថែរក្សារក្សាទ្រព្យសម្បត្តិបរធនបាលកិច្ច និងការស្វែងរកដំណោះស្រាយសម្រាប់បញ្ហាប្រឈមនានារបស់ក្រុមហ៊ុន និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។

## ៣៣. សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា"




*រូបភាព៖ សិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា"។*

នៅថ្ងៃពុធ ១០កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ឈាន សុខារី ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច** បានចូលរួមសិក្ខាសាលាស្តីពី "ការរៀបចំក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា" ដើម្បីពិគ្រោះយោបល់ និងផ្តល់ធាតុចូលក្នុងការរៀបចំជាសេចក្តីព្រាងទស្សនាទានស្តីពីការតាក់តែងក្រមពាណិជ្ជកម្មសម្រាប់កម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ខឿវី វិសុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** នៅសណ្ឋាគារសុខាភ្នំពេញ។ សិក្ខាសាលានេះមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ៣៤. កម្មវិធី “Sustainable Debt and Transition Finance Asia ប្រចាំឆ្នាំ២០២៦”




*រូបភាព៖ កម្មវិធី “Sustainable Debt and Transition Finance Asia ប្រចាំឆ្នាំ២០២៦”។*

នាថ្ងៃអង្គារ ៩ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោកស្រី ស៊ិន សុមាល័យ អនុប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** និង **កញ្ញា សេង ចំណាន មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** ត្រូវបានចាត់ឱ្យចូលរួមកម្មវិធី “Sustainable Debt and Transition Finance Asia ប្រចាំឆ្នាំ-២០២៦” នៅប្រទេសសិង្ហបុរី។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីស្វែងយល់ និងដកស្រង់បទពិសោធន៍ពាក់ព័ន្ធនឹងក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍ បញ្ហាប្រឈម និងនិន្នាការថ្មីៗនៃប្រព័ន្ធអេកូឡូស៊ីហិរញ្ញវត្ថុ ក្នុងការលើកកម្ពស់ហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព ព្រមទាំងការជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជា។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងដោយ Singapore Exchange (SGX) និងមានសិក្ខាកាមចូលរួមមកពីស្ថាប័នរដ្ឋ និងស្ថាប័នឯកជនទាំងក្នុងតំបន់ និងអន្តរជាតិ។

## ៣៥. សកម្មភាពថ្នាក់ដឹកនាំនៃ ន.ប.ធ. កាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ឆ្នាំ២០២៦




*រូបភាព៖ សកម្មភាពថ្នាក់ដឹកនាំនៃ **ន.ប.ធ.** កាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ឆ្នាំ២០២៦។*

នាព្រឹកថ្ងៃព្រហស្បតិ៍ ១១ កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ណាង សេរីរ៉ុថ អនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** និងសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៩ ឆ្នាំ២០២៦ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។

ការប្រឡងគុណវុឌ្ឍិនេះ ជាយន្តការសំខាន់មួយក្នុងការវាយតម្លៃចំណេះដឹង សមត្ថភាពវិជ្ជាជីវៈ និងភាពត្រៀមខ្លួនរបស់បុគ្គលដែលមានបំណងចូលរួម ឬផ្តល់សេវាពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច។ ការប្រឡងនេះ ក៏រួមចំណែកដល់ការពង្រឹងស្តង់ដារវិជ្ជាជីវៈ ការលើកកម្ពស់ការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិ និងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់គាំទ្រដល់ការរីកចម្រើននៃវិស័យបរធនបាលកិច្ចនៅកម្ពុជា។

លើសពីនេះ ពិធីកាត់កញ្ចប់វិញ្ញាសាប្រឡង ត្រូវបានរៀបចំ ក្នុងគោលបំណងធានានូវតម្លាភាព ភាពយុត្តិធម៌ និងសុចរិតភាពនៃដំណើរការប្រឡង។ តាមរយៈការរៀបចំការប្រឡងគុណវុឌ្ឍិនេះ និយ័តករបរធនបាលកិច្ចមានគោលបំណងបន្តពង្រឹងគុណភាពនៃការផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច និងដើម្បីកសាងទំនុកចិត្តបន្ថែមក្នុងចំណោម បរធនបាលទាយក អត្ថគាហកៈ ប្រតិបត្តករបរធនបាល និងគ្រប់ភាគីពាក់ព័ន្ធ។

និយ័តករបរធនបាលកិច្ច បន្តប្តេជ្ញាចិត្តក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយចីរភាព តម្លាភាព និងវិជ្ជាជីវៈខ្ពស់។

## ៣៦. សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយឥណទាន និងកិច្ចពិគ្រោះយោបល់លើនីតិវិធីពាក់ព័ន្ធប្រតិបត្តិការឥណទានខ្សែច្រវាក់តម្លៃកសិកម្មនៃគម្រោងប្រកួតប្រជែង ខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"




*រូបភាព៖ សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយឥណទាន និងកិច្ចពិគ្រោះយោបល់លើនីតិវិធីពាក់ព័ន្ធប្រតិបត្តិការឥណទានខ្សែច្រវាក់តម្លៃកសិកម្មនៃគម្រោងប្រកួតប្រជែង ខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"។*

ព្រឹកថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ **ន.ប.ធ.** ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្មសម្រាប់សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**ក.ស.ហ.វ.**) បានរៀបចំសិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយឥណទាន និងកិច្ចពិគ្រោះយោបល់លើនីតិវិធីពាក់ព័ន្ធប្រតិបត្តិការឥណទានខ្សែច្រវាក់តម្លៃកសិកម្មនៃគម្រោងប្រកួតប្រជែង ខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 នៅសណ្ឋាគារភ្នំពេញ។

កម្មវិធីនេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធអំពីគោលនយោបាយផ្ដល់ឥណទានជាមួយលក្ខខណ្ឌអនុគ្រោះ និងនីតិវិធីប្រតិបត្តិហិរញ្ញប្បទានខ្សែច្រវាក់តម្លៃកសិកម្មរបស់គម្រោង ACSEP។ បច្ចុប្បន្ន អង្គភាពអនុវត្តគម្រោង (ACSEP-PIU1) បានផ្ដល់ឥណទានដែលសរុបជាទឹកប្រាក់មានចំនួន ២៧ លានដុល្លារ-អាមេរិក ដល់អតិថិជនចំនួន ១,២៤២ រូប។

កម្មវិធីនេះ ដោយមានការចូលរួមពី **ឯកឧត្តម យុន លីនណេ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប, **ឯកឧត្តម មូល ធន** អភិបាលរងនៃគណៈអភិបាលខេត្តបាត់ដំបង, **ឯកឧត្តម យុខ គឹមហ៊ាន** អភិបាលរងនៃ

គណៈអភិបាលខេត្តខេត្តព្រះវិហារ, **ឯកឧត្តម ម៉េត មាសភក្ដី** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ, **ឯកឧត្តម ឃ្លោក នួយ** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ, **លោកជំទាវ លំ គន្ធារី** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ធំ, តំណាងក្រសួង-មន្ទីរពាណិជ្ជកម្ម, ក្រសួង-មន្ទីរបរិស្ថាន, ក្រសួង-មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, រដ្ឋបាលខេត្ត និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អង្គភាពគ្រប់គ្រងគម្រោងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (GDICDM), សាជីវកម្មធានាឥណទានកម្ពុជា (CGCC), សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP-PIU1, និងស្ថាប័នហិរញ្ញវត្ថុដៃគូទាំង ៥ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB), ធនាគារស្ថាបនា, ធនាគារប្រៃសណីយ៍កម្ពុជា, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (**ខេមបូឌា**) ភីអិលស៊ី និងធនាគារ អេ អឹម ខេ ម.ក។

## ៣៧. សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "នីតិវិធីនៃការរៀបចំនិងការគ្រោងថវិកា និងគោលការណ៍ណែនាំបើកប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសរបស់ ន.ប.ធ"



*រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "នីតិវិធីនៃការរៀបចំនិងការគ្រោងថវិកា និងគោលការណ៍ណែនាំបើកប្រាក់បេសកកម្មក្នុង និងក្រៅប្រទេស របស់ ន.ប.ធ"។*

នាថ្ងៃព្រហស្បតិ៍ ១១កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៦ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ន.ប.ធ.** បានរៀបចំកម្មវិធីសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "នីតិវិធីនៃការរៀបចំនិងការគ្រោងថវិកា និងគោលការណ៍ណែនាំបើកប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសរបស់ **ន.ប.ធ**" ក្រោមអធិបតីភាពរបស់ **លោក យុន វាសនា** អគ្គនាយករងនៃ **ន.ប.ធ.** តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅសណ្ឋាគារ អេមព្រីស អង្គរ ខេត្តសៀមរាប ដើម្បីជាត្រីវិស័យក្នុងការតម្រង់ទិសការងាររៀបចំកញ្ចប់ថវិកាឱ្យមានសង្គតិភាព ឆ្លើយតបទៅនឹងតម្រូវការជាក់ស្ដែងរបស់ស្ថាប័ន ព្រមទាំង ធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្តការងារហិរញ្ញវត្ថុ សំដៅរួមចំណែកជំរុញការអភិវឌ្ឍវិស័យបរធនបាលកិច្ចនៅកម្ពុជាឱ្យកាន់តែរីកចម្រើន។

## ៣៨. សាលាផ្សព្វផ្សាយអំពី "កិច្ចគាំពារវិនិយោគិន និងពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"




*រូបភាព៖ សាលាផ្សព្វផ្សាយអំពី "កិច្ចគាំពារវិនិយោគិន និងពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច"។*

នៅព្រឹកថ្ងៃសុក្រ ១២កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស២៥៧០ ត្រូវនឹងថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានសហការជាមួយរដ្ឋបាលខេត្តសៀមរាបរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី "កិច្ចគាំពារវិនិយោគិន និងពង្រឹងការអនុវត្តច្បាប់ក្នុងវិស័យបរធនបាលកិច្ច ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោក សុខ ថុល អភិបាលរងខេត្តសៀមរាប** នៅសណ្ឋាគារ អេមព្រីសអង្គររីសត និងស្ប៉ា ខេត្តសៀមរាប ដល់តំណាងរដ្ឋបាលចំណុះខេត្តសៀមរាបរួមមាន មន្ទីរ-ស្ថានប័នពាក់ព័ន្ធ តំណាងសាលាដំបូងខេត្តសៀមរាប សាខាពន្ធដារ សាខាគយនិងរដ្ឋាករ កងរាជអាវុធហត្ថ ព្រមទាំងតំណាងសភាពាណិជ្ជកម្មខេត្តសៀមរាប សមាគមធុរកិច្ច ក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាល និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពី ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ច យន្តការការពារទ្រព្យ-សម្បត្តិបរធនបាលកិច្ច និងកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនក្នុងវិស័យបរធនបាលកិច្ច ដើម្បីបង្កើនប្រសិទ្ធភាពអនុលោមភាពតាមច្បាប់ក្នុងវិស័យបរធនបាលកិច្ច។

## ៣៩. កម្មវិធីអបអរសាទរទិវា ជាតិសហគ្រាសធុនមីក្រូតូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦” ក្រោមប្រធានបទ "សាងស្ពាន សម្រាប់ MSMEs ឆ្ពោះទៅកាន់ទីផ្សារ




*រូបភាព៖ កម្មវិធីអបអរសាទរទិវា ជាតិសហគ្រាសធុនមីក្រូតូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦″ ក្រោមប្រធានបទ "សាងស្ពាន សម្រាប់ MSMEs ឆ្ពោះទៅកាន់ទីផ្សារ។*

ដោយមានការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), នារសៀលថ្ងៃសៅរ៍ ១៣កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមក្នុង "កម្មវិធីអបអរសាទរទិវា ជាតិសហគ្រាសធុនមីក្រូតូច និងមធ្យម លើកទី៣ ឆ្នាំ២០២៦″ ក្រោមប្រធានបទ "សាងស្ពាន សម្រាប់ MSMEs ឆ្ពោះទៅកាន់ទីផ្សារ" នៅសណ្ឋាគារ សាំងគ្រីឡាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ហែម វណ្ណឌី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**។

## ៤០.សិក្ខាសាលាស្តីពី "ការបង្កើត និងចុះបញ្ជីបរធនបាលកិច្ច អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដល់អង្គការសមាគមស្ថិតក្រោមក្រសួងមហាផ្ទៃ"



***រូបភាព៖*** *សិក្ខាសាលាស្តីពី "ការបង្កើត និងចុះបញ្ជីបរធនបាលកិច្ច អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដល់អង្គការសមាគមស្ថិតក្រោមក្រសួងមហាផ្ទៃ"។*

នាព្រឹកថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), ក្រសួងមហាផ្ទៃ និងរដ្ឋបាលសាលាខេត្តតាកែវ បានសហការរៀបចំសិក្ខាសាលាស្តីពី "ការបង្កើត និងចុះបញ្ជីបរធនបាលកិច្ច អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ចដល់អង្គការសមាគមស្ថិតក្រោមក្រសួងមហាផ្ទៃ" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម ឧត្តមសេនីយ៍ឯក ខិន ចាណារ៉ា** អគ្គនាយករងនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ និង **លោក ស៊ុត ខុន អភិបាលរងនៃគណៈអភិបាលខេត្តតាកែវ** នៅរដ្ឋបាលខេត្តតាកែវ។ សិក្ខាសាលានេះត្រូវបានរៀបចំ ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមដល់សិក្ខាកាមពីក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានពីការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ចអំពីដំណើរការបង្កើត ការចុះបញ្ជី និងប្រតិបត្តិការសកម្មភាពក្នុងក្របខណ្ឌបរធនបាលកិច្ចសង្គម។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់ មន្ត្រីជំនាញនៃ **ន.ប.ធ.** តំណាងក្រសួងមហាផ្ទៃ អង្គភាពមន្ទីរ ចំណុះឲ្យរដ្ឋបាលសាលាខេត្តតាកែវ និងតំណាងអង្គការ-សមាគមពាក់ព័ន្ធ។

## ៤១. កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦




*រូបភាព៖ កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦។*

នាព្រឹកថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦, **លោក យុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងរបស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីត្រួតពិនិត្យ និងពិភាក្សាលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ Zoom។

## ៤២. កិច្ចប្រជុំក្រុមការងារចំពោះកិច្ចទទួលបន្ទុករៀបចំការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល




*រូបភាព៖ កិច្ចប្រជុំក្រុមការងារចំពោះកិច្ចទទួលបន្ទុករៀបចំការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល។*

នារសៀលថ្ងៃចន្ទ ១៥កើត ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៦ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារចំពោះកិច្ចទទួលបន្ទុករៀបចំការបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលរបស់រាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាទៅលើ៖ ១) វឌ្ឍនភាពរបស់គណៈកម្មាធិការអន្តរក្រសួងលើការលើកកម្ពស់ប្រាក់រៀល, ២) ការរៀបចំ សេចក្តីព្រាងឯកសារគោលនយោបាយស្តីពីប្រាក់រៀល, ៣) ការលើកកម្ពស់ការបោះផ្សាយមូលបត្ររដ្ឋជាប្រាក់រៀល និង ៤) ប្រតិបត្តិការសារពើពន្ធរបស់រាជរដ្ឋាភិបាលជាប្រាក់រៀល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា អ.ស.ហ.** និង **ឯកឧត្តម ឃឹម លាត ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា** ព្រមទាំងមានការអញ្ជើញចូលរួមពី សមាជិក-សមាជិកានៃក្រុមការងារចំពោះកិច្ចទទួលបន្ទុករៀបចំបង្កើតគណៈកម្មាធិការជាតិលើកកម្ពស់ការប្រើប្រាស់ ប្រាក់រៀលរបស់រាជរដ្ឋាភិបាល ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**), អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) និងប្រចាំធនាគារជាតិនៃកម្ពុជា នៅទីស្តីការធនាគារជាតិនៃកម្ពុជា អគារសែនសុខ ។

## ៤៣. សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"









*បកាព៖ សិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច"។*

នាព្រឹកថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "យន្តការ និងអត្ថប្រយោជន៍របស់បរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **ឯកឧត្តម លីម ប៊ុនហុក សហនាយកនៃវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ** នៅវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ សម្រាប់និស្សិតនៅវិទ្យាស្ថាន អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិត ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

តាមរយៈ សិក្ខាសាលានេះ និស្សិតអាចយល់ដឹងបន្ថែម អំពីតួនាទីរបស់បរធនបាលកិច្ចក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការពង្រឹងទំនុកចិត្តក្នុងវិស័យហិរញ្ញវត្ថុនៅកម្ពុជា។

កម្មវិធីនេះក៏បានបើកឱកាសឱ្យនិស្សិតចូលរួមពិភាក្សា និងសួរសំណួរពាក់ព័ន្ធនឹងការអនុវត្តបរធនបាលកិច្ចនៅកម្ពុជាផងដែរ។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីមន្ត្រីជំនាញ,សាស្ត្រាចារ្យ និងនិស្សិតនៃវិទ្យាស្ថានសិក្សាបច្ចេកទេសធនាគារ។

## ៤៤. កិច្ចប្រជុំពិភាក្សាលើកទី២ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥






*រូបភាព៖ កិច្ចប្រជុំពិភាក្សាលើកទី២ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។*

នាព្រឹកថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦, **លោក ឃុន វាសនា** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច ( **ន.ប.ធ.** ) តំណាងរបស់**ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក លឹម ឡៃត ប្រធានស្តីទីនាយកដ្ឋានកិច្ចការទូទៅ** និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើកទី២ លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិការបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ ក្រោមអធិបតីភាពរបស់ **ឯកឧត្តមបណ្ឌិត ជូ គឹមឡេង រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ Zoom។

## ៤៥. វគ្គបណ្តុះបណ្តាលស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ដល់បរធនបាលនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ ន.ប.ធ.





*រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី" កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ដល់បរធនបាលនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ ន.ប.ធ.។*

នៅរសៀលថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ពុទ្ធសករាជ ២៥៧០ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច ( **ន.ប.ធ.** ), **លោក រិន រដ្ឋា ប្រធាននាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច**នៃ **ន.ប.ធ.** បានដឹកនាំមន្ត្រីជំនាញ ដើម្បីផ្តល់ការបណ្តុះបណ្តាលស្តីពី "កាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាល" ដល់បរ-ធនបាលនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ **ន.ប.ធ.** នៅទីស្តីការរបស់ **ន.ប.ធ.**។ វគ្គបណ្តុះបណ្តាល

នេះ រៀបចំឡើងក្នុងគោលបំណង ដើម្បីបញ្ជ្រាបការយល់ដឹងបន្ថែមពាក់ព័ន្ធនឹងកាតព្វកិច្ចផ្តល់របាយការណ៍ ជូនដំណឹង និងស្នើសុំការអនុញ្ញាតរបស់បរធនបាលនៃបរធនបាលកិច្ចសាធារណៈ ដោយមានការចូលរួមពីបរធនបាល និងតំណាងបរធនបាលនៃបរធនបាលកិច្ចសាធារណៈដែលបានចុះបញ្ជីនៅ **ន.ប.ធ.** សំដៅដល់ការអនុវត្តប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព និងមានរបៀបរៀបរយ ដោយអនុលោមតាមច្បាប់ស្តីពីបរធនបាលកិច្ច និងបទប្បញ្ញត្តិក្នុងវិស័យបរធនបាលកិច្ចជាធរមាន។

## ៤៦.មន្ត្រីជំនាញនៃ ន.ប.ធ. ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្មដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធនដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ ន.ប.ធ.




*... ពី បរធនបាលកិច្ចនៅ ន.ប.ធ.។*

នៅថ្ងៃចន្ទ ១៥កើត និងថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី២៩-៣០ ខែមិថុនា ឆ្នាំ២០២៦ ដោយទទួលបានការអនុញ្ញាត និងការចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក ហេង បញ្ញា ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសង្គម និងបុគ្គល** និង **លោក អ៊ឹង ឡេង ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** បាន ដឹកនាំ មន្ត្រីជំនាញនៃ **ន.ប.ធ.** ចុះត្រួតពិនិត្យដល់ទីកន្លែងទីតាំងអចលនវត្ថុនៃបរធនបាលកិច្ចពាណិជ្ជកម្ម ដែលស្ថិតនៅរាជធានីភ្នំពេញ និងខេត្តកំពង់ស្ពឺ ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណបរធន និងទីតាំងជាក់ស្តែងនៃទ្រព្យសម្បត្តិបរធនបាលកិច្ចដែលកំពុងស្នើសុំបង្កើត និងចុះបញ្ជីបរធនបាលកិច្ចនៅ **ន.ប.ធ.** ដោយក្រុមហ៊ុនបរធនបាលដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។

# និយ័តករបរធនបាលកិច្ច

TRUST REGULATOR

## បរធនបាលកិច្ច លើសពីថ្នាលបង្កើតទំនុកចិត្ត ក្នុងធុរកិច្ច

អគារ ១៦៨ ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1 Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia ☎ (855) 23 237 888